# ពិធីផ្សព្វផ្សាយ
# ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.) ២០១៩-២០២៣
# នៅថ្នាក់ក្រោមជាតិ

# ខ្លឹមសាររបស់
# ផ.យ.អ.ជ. ២០១៩-២០២៣

អគ្គនាយកដ្ឋានផែនការ ក្រសួងផែនការ

*ខេត្តតាកែវ ថ្ងៃទី២០ ខែមករា ឆ្នាំ២០២០*
*ខេត្តសៀមរាប ថ្ងៃទី២២ ខែមករា ឆ្នាំ២០២០*
*ខេត្តក្រចេះ ថ្ងៃទី២៣ ខែមករា ឆ្នាំ២០២០*

# មាតិកា របស់ ផ.យ.អ.ជ. ២០១៩-២០២៣

- ជំពូកទី១៖ ទិដ្ឋភាពរួមនៃការវិវត្តនិងភាពជោគជ័យក្នុងការអនុវត្តគោលនយោបាយ របស់រាជរដ្ឋាភិបាលកម្ពុជា។
- ជំពូកទី២៖ សមិទ្ធផលនិងបញ្ហាប្រឈមនានា ដែលជួបប្រទះ នៅក្នុងពេលអនុវត្ត ផ.យ.អ.ជ. ២០១៤-២០១៨។
- ជំពូកទី៣៖ ស្ថានភាពរួមនៃម៉ាក្រូសេដ្ឋកិច្ច និងទិសដៅសម្រាប់៥ឆ្នាំបន្ទាប់
- ជំពូកទី៤៖ គោលនយោបាយអាទិភាពសំខាន់ៗ និង សកម្មភាព កម្មវិធី និង គម្រោងសំខាន់ៗ។
- ជំពូកទី៥៖ ការកំណត់តម្រូវការធនធាន និងកម្មវិធីចំណាយសម្រាប់អនុវត្ត សកម្មភាព កម្មវិធី និងគម្រោង ដែលបានលើកឡើង ក្នុងជំពូកទី៤។
- ជំពូកទី៦៖ យន្តការសម្រាប់ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ផ.យ.អ.ជ. ២០១៩-២០២៣
- ជំពូកទី៧៖ សេចក្តីសន្និដ្ឋានរួម។

# ១. ខ្លឹមសារនៃ ផ.យ.អ.ជ. ២០១៩-២០២៣

- ការកំណត់ខ្លឹមសាររបស់ផែនការត្រូវបានផ្តោតលើ៖
  - ការកំណត់សកម្មភាពអាទិភាពរបស់ក្រសួង ស្ថាប័ន នានា សម្រាប់អនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា តាមវិស័យ/មុំនីមួយៗរបស់យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ និងគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា។
  - ការកំណត់បរិមាណថវិកាចំណាយ សម្រាប់អនុវត្តសកម្មភាពអាទិភាព តាមវិស័យ ដោយផ្អែកលើក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច សម្រាប់រយៈពេល ៥ឆ្នាំ ២០១៩-២០២៣។
  - ការប៉ាន់ស្មានបរិមាណធនធានសរុប ពីគ្រប់ប្រភពទាំងអស់ ដែលអាចមាន ឬដែលចាំបាច់ត្រូវកៀរគរ ដើម្បីអនុវត្តឱ្យសម្រេចបាននូវចំណុចដៅទាំងឡាយរបស់ផែនការ។

# ១. ខ្លឹមសារនៃ ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

- ទម្រង់នៃ ផ.យ.អ.ជ. ២០១៩-២០២៣ ជំពូកទី៤ ត្រូវបានរៀបចំតាមទម្រង់នៃយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ ដែលមាន៖
  - ✓ សំណុំចតុកោណចំនួន ៦ ហើយ
  - ✓ សំណុំនីមួយៗ មានមុំ ៤ ដែលគ្របដណ្តប់លើគ្រប់វិស័យទាំងអស់។

# ១. ខ្លឹមសារនៃ ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

## ១. ការបង្កើនល្បឿនកែទម្រង់អភិបាលកិច្ចល្អ: ស្នូលនៃយុទ្ធសាស្ត្រចតុកោណ

### ១.១. ការកែទម្រង់ និង លើកកម្ពស់សមត្ថភាពស្ថាប័ន

**រាជរដ្ឋាភិបាលកម្ពុជានឹងផ្តោតអាទិភាពលើការងារស្នូលចំនួន៥ ដូចខាងក្រោម៖**

- ការធ្វើវិចារណកម្មមុខងារ និង ភារកិច្ច រចនាសម្ព័ន្ធគ្រប់គ្រងស្ថាប័ន
- ការពង្រឹងភាពជាអ្នកដឹកនាំ ស្មារតីម្ចាស់ការប្រកបដោយការទទួលខុសត្រូវខ្ពស់ និង សាមគ្គីភាពផ្ទៃក្នុងស្ថាប័ន
- ការលើកកម្ពស់គុណភាពក្នុងការជ្រើសរើស ការតែងតាំង ការដំឡើងថ្នាក់ និង ឋានន្តរស័ក្តិ
- ការពង្រឹងសមត្ថភាពគ្រប់គ្រងវិស័យសាធារណៈ
- ការបន្តកែទម្រង់កងកម្លាំងប្រដាប់អាវុធ

# ១. ខ្លឹមសារនៃ ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

## ១. ការបង្កើនល្បឿនកែទម្រង់អភិបាលកិច្ចល្អ: ស្នូលនៃយុទ្ធសាស្ត្រចតុកោណ (ត)

### ១.២. ការពង្រឹងភាពស្អាតស្អំក្នុងរដ្ឋបាលសាធារណៈ

**រាជរដ្ឋាភិបាលកម្ពុជា នឹងផ្តោតលើការងារអាទិភាពចំនួន៦ គឺ៖**

- ការសម្រួច យុទ្ធសាស្ត្រអប់រំ បង្ការ ទប់ស្កាត់ និង បង្ក្រាប ដោយផ្អែកលើផែនការយុទ្ធសាស្ត្រជាតិប្រយុទ្ធ ប្រឆាំងនឹងអំពើពុករលួយ
- ការពង្រឹង និង ពង្រីកការផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានបច្ចុប្បន្នភាពស្តីពី សេវាសាធារណៈ លិខិតបទដ្ឋានគតិយុត្ត និង ឯកសារគោលនយោបាយជាតិ
- ការជំរុញឱ្យ មានការចូលរួមពីសំណាក់ប្រជាជន ក្នុងដំណើការនៃការអភិវឌ្ឍ ការរៀបចំគោលនយោបាយ និង ការអនុវត្ត
- ការជំរុញការអនុវត្តយន្តការទទួលព័ត៌មានត្រឡប់ និង ដោះស្រាយបណ្តឹង តវ៉ារបស់អ្នកប្រើប្រាស់សេវា
- ការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយន្តការអធិការកិច្ច និងសវនកម្មក្នុងវិស័យសាធាណៈ
- ការពង្រឹងប្រសិទ្ធភាពរៀបចំ និង អនុវត្តក្រមសីលធម៌ការងារ

# ១. ខ្លឹមសារនៃ ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

## ១. ការបង្កើនល្បឿនកែទម្រង់អភិបាលកិច្ចល្អ: ស្នូលនៃយុទ្ធសាស្ត្រចតុកោណ (ត)

### ១.៣. ការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តការងារ

**រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ**

- ការបន្តជំទើ្ឡងបៀវត្សជូនមន្ត្រីរាជការស៊ីវិលនិងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ
- ការធ្វើប្រតិភូកម្មអំណាច ការផ្ទេរមុខងារ ការផ្ទេរធនធាន និង ការចែករំលែកបច្ចេកទេស តាមរយៈយន្តការវិមជ្ឈការនិងវិសហមជ្ឈការ
- ការជំរុញនវានុវត្ត និង រដ្ឋបាលឯកភាព នៅក្នុងកម្រិតក្រុង ស្រុក- ខណ្ឌ ខេត្ត-រាជធានី
- ការដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រង ផ្អែកលើសមិទ្ធកម្ម ដោយប្រើប្រាស់សូចនាករសមិទ្ធកម្មគន្លឹះ
- ការដាក់ឱ្យអនុវត្តយន្តការតាមដាន និង វាយតម្លៃ
- ការពង្រឹងយន្តការចែករំលែក និង ការផ្លាស់ប្តូរព័ត៌មានក្នុងរដ្ឋបាលសាធារណៈនៅគ្រប់កម្រិត
- ការលើកកម្ពស់សេវាយុត្តិធម៌

# ១. ខ្លឹមសារនៃ ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

## ១. ការបង្កើនល្បឿនកែទម្រង់អភិបាលកិច្ចល្អ: ស្នូលនៃយុទ្ធសាស្ត្រចតុកោណ (ត)

### ១.៤ ការពង្រឹងអភិបាលកិច្ចវិស័យឯកជន

**រាជរដ្ឋាភិបាលកម្ពុជានឹង ផ្តោតអាទិភាពលើ៖**

- ការសិក្សា និង ការរៀបចំក្របខណ្ឌគោលនយោបាយលើកកម្ពស់អភិបាលកិច្ចក្នុងវិស័យឯកជន
- ការសិក្សា និង រៀបចំក្របខណ្ឌគោលនយោបាយលើកកម្ពស់ការទទួលខុសត្រូវផ្នែកសង្គម និង បរិស្ថាន
- ការបន្តអនុវត្តយន្តការ សន្ទនាក្នុងភាពជាដៃគូរវាងរដ្ឋ និង វិស័យឯកជន ក្នុងកម្រិតគោលនយោបាយ និង បច្ចេកទេស ទាំងនៅថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ
- ការជំរុញ និង ការលើកទឹកចិត្តឱ្យវិស័យឯកជនវិនិយោគឡើងវិញ លើការចូលរួមអភិវឌ្ឍមូលធនមនុស្ស និង នវានុវត្តន៍

# ១. ខ្លឹមសារនៃ ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

## ២- បរិស្ថានគ្រប់ដណ្ដប់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រនាំមុខ

### ២.១. សន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ

**រាជរដ្ឋាភិបាលកម្ពុជានឹងបន្តផ្តោតអាទិភាព លើ៖**

- ការការពារអធិបតេយ្យជាតិ និង បូរណភាពទឹកដី ព្រមទាំងការទប់ស្កាត់ និង ប្រឆាំងដាច់ខាតរាល់សកម្មភាពផ្សេងៗដែលពាក់ព័ន្ធនឹងបដិវត្តន៍ពណ៌ ឬ ការញុះញង់
- ការបន្តពង្រឹងនីតិ រដ្ឋ លទ្ធិប្រជាធិបតេយ្យ វប្បធម៌សន្តិភាព សីលធម៌ សង្គម ការគោរពសិទ្ធិ និង សេចក្តីថ្លៃថ្នូរ របស់
- ការបន្តដោះស្រាយបញ្ហាព្រំដែនគោក និង ទឹកជាមួយប្រទេសជិតខាង ដោយផ្អែកលើមូលដ្ឋានច្បាប់អន្តរជាតិ
- ការទប់ស្កាត់ និង បង្ក្រាបបទល្មើសព្រហ្មទណ្ឌគ្រប់ប្រភេទ
- ការបន្តពង្រឹងសុវត្ថិភាពចរាចរណ៍ និង សណ្តាប់ធ្នាប់សាធារណៈ
- ការបន្តពង្រឹងការអនុវត្តច្បាប់សញ្ជាតិ និង ច្បាប់អន្តោប្រវេសន៍
- ការពង្រឹងការអនុវត្តច្បាប់ និង កសាងសមត្ថភាពដើម្បីទប់ស្កាត់ បទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យា

# ១. ខ្លឹមសារនៃ ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

## ២- បរិស្ថានគ្រួបដណ្ដប់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រចតុកោណ (ត)

### ២.២- បរិយាកាសអំណោយផល សម្រាប់ធុរកិច្ច ការវិនិយោគ និង ការអភិវឌ្ឍ

**រាជរដ្ឋាភិបាលនឹងផ្ដោតអាទិភាពលើ៖**

- ❑ ការបន្តអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ដោយប្រុងប្រយ័ត្ន ដោយប្រកាន់យកនូវការផ្សំនៃគោលនយោបាយហិរញ្ញវត្ថុសាធារណៈ គោលនយោបាយរូបិយវត្ថុ និង ការកែទម្រង់រចនាសម្ព័ន្ធ
- ❑ ការរៀបចំនូវយន្តការគ្រប់គ្រងវិបត្តិ និង ហានិភ័យផ្នែកសេដ្ឋកិច្ច ដែលអាចកើនឡើងក្នុងវិស័យហិរញ្ញវត្ថុ
- ❑ ការជំរុញបញ្ចប់ការធ្វើវិសោធនកម្មច្បាប់ស្ដីពីវិនិយោគ និង ការជំរុញការអនុវត្ត
- ❑ ការជំរុញរៀបចំការកែទម្រង់ប្រព័ន្ធពន្ធដារគ្រប់ជ្រុងជ្រោយ និង ស៊ីជម្រៅ រួមទាំងការរៀបចំច្បាប់ស្ដីពីសារពើពន្ធថ្មី
- ❑ ការរៀបចំ និង ជំរុញអនុវត្តនូវយន្តការសម្រួលដល់ការបង្កើតធុរកិច្ចថ្មី
- ❑ ការបន្តជំរុញកិច្ចសម្រួលពាណិជ្ជកម្ម ការកែលម្អយន្តការត្រួតពិនិត្យនៅតាមព្រំដែនឱ្យស្ថិតក្នុងកម្រិតអប្បបរមា និង ការបន្តកាត់បន្ថយនីតិវិធី ដែលមិនចាំបាច់ និង ជាឧបសគ្គដល់ពាណិជ្ជកម្ម។

# ១. ខ្លឹមសារនៃ ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

## ២- បរិស្ថានគ្រប់ដណ្ដប់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រចតុកោណ (ត)

### ២.៣. ការពង្រឹងភាពម្ចាស់ ភាពជាដៃគូក្នុងការអភិវឌ្ឍ និងសហប្រតិបត្តិការអន្តរជាតិ

**រាជរដ្ឋាភិបាលផ្ដោតការយកចិត្តទុកដាក់លើ៖**

- ការបន្តពង្រឹងភាពជាដៃគូប្រកបដោយបរិយាប័ន្ន ជាមួយបណ្ដាតួអង្គអភិវឌ្ឍដើម្បីកៀរគរធនធានហិរញ្ញប្បទាន សម្រាប់ធ្វើឱ្យសម្រេចបាននូវគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា
- ការរៀបចំ និង អនុវត្ត "យុទ្ធសាស្ត្រស្ដីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍ និង ភាពជាដៃគូឆ្នាំ ២០១៩-២០២៣" ដើម្បីពង្រឹងភាពជាម្ចាស់របស់រាជរដ្ឋាភិបាល
- ការបន្តចូលរួមយ៉ាងសកម្មក្នុងកិច្ចការតំបន់ និង ពិភពលោក
- ការបន្តអនុវត្តនូវការប្ដេជ្ញាចិត្តដែលកម្ពុជាបានឯកភាពនៅក្នុង វេទិកាអន្តរជាតិស្ដីពីស័ក្ដិសិទ្ធភាពក្នុងកិច្ចអភិវឌ្ឍ
- ការបន្តពង្រឹងភាពជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាល តាមរយៈការពង្រឹងការអនុវត្តច្បាប់ស្ដីពីសមាគម និង អង្គការមិនមែនរដ្ឋាភិបាល
- ការបន្តពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ និង ការបង្កើតបន្ថែមនូវយន្តការថ្មីៗដើម្បីទាក់ទាញការវិនិយោគថែមទៀត

# ១. ខ្លឹមសារនៃ ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

## ២- បរិស្ថានគ្រប់ដណ្ដប់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រនាំមុខ (ត)

### ២.៤. ការពង្រឹងសមត្ថភាពកម្ពុជា ដើម្បីបន្តជំរុញសមាហរណកម្មខ្លួនចូលក្នុងសេដ្ឋកិច្ចតំបន់ និង ពិភពលោក

**រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ៖**

- ការបន្តខិតខំបំពេញនូវកាតព្វកិច្ចសេសសល់នានា ក្នុងក្របខណ្ឌអង្គការពាណិជ្ជកម្មពិភពលោក សហគមន៍សេដ្ឋកិច្ចអាស៊ាន និង ក្របខណ្ឌទ្វេភាគី
- ការជំរុញបង្កើតតំបន់ពាណិជ្ជកម្មសេរីទ្វេភាគីជាមួយដៃគូពាណិជ្ជកម្មសំខាន់ៗ និងបង្កើតតំបន់ពាណិជ្ជកម្ម សេរីពហុភាគីជាមួយនឹងតំបន់សំខាន់ៗ
- ការបន្តពង្រឹងការតភ្ជាប់ផ្នែកធុរកិច្ច ដោយរៀបចំឱ្យមានវេទិកាដំណើរទស្សនកិច្ច ឬការតាំងបង្ហាញផលិតផល
- ការបន្តជំរុញការចូលរួមដោយសកម្មរបស់កម្ពុជា ក្នុងកិច្ចសហប្រតិបត្តិការ និងគំនិតផ្តួចផ្តើមក្នុងផ្នែកសមាហរណកម្មសេដ្ឋកិច្ចនៅកម្រិតអន្តរជាតិ តំបន់ និង ទ្វេភាគី។
- ការជំរុញកិច្ចសហប្រតិបត្តិការ និង ការសម្របសម្រួលរវាងក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាល និង គ្រប់តួអង្គអភិវឌ្ឍផ្សេងទៀត
- ការបន្តកសាងសមត្ថភាព សម្រាប់ការតាមដាននិន្នាការពាណិជ្ជកម្មនៅគ្រប់វិស័យ។

# ១. ខ្លឹមសារនៃ ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

## ៣- ការអភិវឌ្ឍធនធានមនុស្ស

### ៣.១- ការពង្រឹងគុណភាពវិស័យអប់រំ វិទ្យាសាស្ត្រ និង បច្ចេកវិទ្យា

**រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ៖**

- ការបន្តដំឡើងបៀវត្ស និង ប្រាក់លើកទឹកចិត្តផ្អែកតាមសមិទ្ធកម្មជូន គ្រូបង្រៀន និង បុគ្គលិកអប់រំ ការលើកកម្ពស់សមត្ថភាពគ្រប់គ្រងរបស់នាយកសាលា ការបន្តលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន សមត្ថភាពបង្រៀន
- ការបន្តវិនិយោគលើការកសាងសាលាបឋមសិក្សាឱ្យបានដល់ភូមិ និង អនុវិទ្យាល័យឱ្យបានគ្រប់ឃុំតាមការចាំបាច់ផ្អែកលើស្ថានភាពសង្គម-សេដ្ឋកិច្ច
- ការពង្រឹងអធិការកិច្ចគ្រប់ជ្រុងជ្រោយលើការគ្រប់គ្រងសាលារៀន
- ការធ្វើបច្ចុប្បន្នភាព និង ការជំរុញការអនុវត្តផែនការគោលសម្រាប់ការអប់រំបច្ចេកទេសនៅមធ្យមសិក្សាទុតិយភូមិ
- ការបង្កើនភាពឆ្លើយតបឱ្យកាន់តែពេញលេញនៃការអប់រំទៅនឹងទីផ្សារការងារ
- ការរៀបចំក្របខណ្ឌកម្មវិធីសិក្សាគោលគ្រប់ជ្រុងជ្រោយ
- ការត្រៀមប្រកួតកីឡាស៊ីហ្គេមឆ្នាំ ២០២៣

# ១. ខ្លឹមសារនៃ ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

## ៣- ការអភិវឌ្ឍធនធានមនុស្ស (ត)

### ៣.២. ការបណ្តុះបណ្តាលជំនាញបច្ចេកទេស

**រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ៖**

- ការបន្តជំរុញការអនុវត្ត *"គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឆ្នាំ ២០១៧-២០២៥"*
- ការបង្កើនកិច្ចសហការរវាងសាលារៀន និង សហគ្រាស ក្នុងការបណ្តុះបណ្តាលសំដៅបង្កើនសមត្ថភាព ជំនាញបច្ចេកទេស និង ផលិតភាពរបស់កម្លាំងពលកម្ម
- ការបន្តរៀបចំមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញតាមតម្រូវការជាក់ស្តែងរបស់វិស័យនីមួយៗ
- ការធ្វើវិចារណកម្ម និង អភិវឌ្ឍគ្រឹះស្ថានបណ្តុះបណ្តាលជំនាញបច្ចេកទេស និង វិជ្ជាជីវៈ ក្នុងការផ្តត់ផ្គង់ជំនាញ ច្រើនប្រភេទ
- ការតម្រង់ទិសវិជ្ជាជីវៈនៅតាមអនុវិទ្យាល័យ និង វិទ្យាល័យក្នុងប្រព័ន្ធអប់រំចំណេះទូទៅ

# ១. ខ្លឹមសារនៃ ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

## ៣- ការអភិវឌ្ឍធនធានមនុស្ស (ត)

### ៣.៣- ការលើកកម្ពស់សេវាសុខភាពសាធារណៈ និង អាហារូបត្ថម្ភ

**រាជរដ្ឋាភិបាលនឹងផ្ដោតអាទិភាពលើ៖**

- ការបន្តជំរុញការអនុវត្ត និង ធ្វើបច្ចុប្បន្នកម្ម *"ផែនការយុទ្ធសាស្ត្រសុខាភិបាល ២០១៦-២០២០"*
- ការជំរុញវិសាលភាពគ្របដណ្ដប់សុខភាពសកលនៅកម្ពុជា
- ការលើកកម្ពស់គុណភាព សុវត្ថិភាព និង ប្រសិទ្ធភាព សេវាសុខភាព
- ការរៀបចំ និង អនុវត្តឱ្យមានប្រសិទ្ធភាព នូវផែនការយុទ្ធសាស្ត្រ អភិវឌ្ឍធនធានមនុស្សក្នុងវិស័យសុខាភិបាល
- ការពង្រឹងការអនុវត្តច្បាប់ និង បទប្បញ្ញត្តិពាក់ព័ន្ធនឹងការគ្រប់គ្រង និង ការត្រួតពិនិត្យគុណភាពផលិតផលឱសថ ការប្រើប្រាស់ឱសថដោយគ្មានវេជ្ជបញ្ជា ការប្រើសារធាតុគីមីក្នុងចំណីអាហារ និង ការប្រើគ្រឿងស្រវឹង និង ថ្នាំជក់។
- ការជំរុញអនុវត្តវិធានការទប់ស្កាត់ បង្ការ និង កាត់បន្ថយជំងឺ
- ការដាក់ឱ្យអនុវត្តកម្មវិធីឧបត្ថម្ភស្ត្រីមានផ្ទៃពោះ និង កុមារអាយុក្រោម ២ ឆ្នាំ នៃ គ្រួសារក្រីក្រ ការរៀបចំកិច្ចអន្តរាគមន៍ផ្សេងៗសំដៅលើកកម្ពស់អាហារូបត្ថម្ភ និង រៀបចំឱ្យមានយន្តការពហុវិស័យ

# ១. ខ្លឹមសារនៃ ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

## ៣- ការអភិវឌ្ឍធនធានមនុស្ស (ត)

### ៣.៤. ការពង្រឹងសមភាពយេនឌ័រ និង ការគាំពារសង្គម

**រាជរដ្ឋាភិបាលកម្ពុជា មានគោលដៅជាយុទ្ធសាស្ត្រ ច្បាស់លាស់ គឺ៖**

- ការបន្តលើកកម្ពស់តួនាទីស្ត្រី តាមរយៈការបង្កើនសមាមាត្រ និង ការពង្រឹងសមត្ថភាពស្ត្រីក្នុងជួរថ្នាក់ដឹកនាំ ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- ការធ្វើបច្ចុប្បន្នភាព និង អនុវត្ត "ផែនការយុទ្ធសាស្ត្រនារីរតនៈ"
- ការជំរុញអនុវត្ត *"ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥"*
- ការរៀបចំក្របខណ្ឌគតិយុត្ត និង ហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ដើម្បីដាក់ឱ្យដំណើរការ កម្មវិធីជាតិជំនួយសង្គមថ្មីៗ

# ១. ខ្លឹមសារនៃ ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

## ៤. ការធ្វើពិពិធកម្មសេដ្ឋកិច្ច

### ៤.១. ការកែលម្អប្រព័ន្ធឡូជីស្ទីក, ការលើកកម្ពស់ការតភ្ជាប់ផ្នែកដឹកជញ្ជូន ថាមពល និង ឌីជីថល

**រាជរដ្ឋាភិបាលក្នុងនីតិកាលទី ៦ នឹងផ្តោតអាទិភាពលើ៖**

- អនុម័ត និង ការអនុវត្តផែនការមេសម្រាប់វិស័យដឹកជញ្ជូនពហុមធ្យោបាយ និងឡូជីស្ទីក
- ការបន្តបង្កើនថវិកាវិនិយោគ និង កៀរគរហិរញ្ញប្បទាន ដើម្បីស្ថាបនា និង អភិវឌ្ឍហេ ដ្ឋារចនាសម្ព័ន្ធរូបវន្ត ទាំងផ្លូវគោក ស្ពាន ផ្លូវដែក ផ្លូវទឹក និង ផ្លូវអាកាស
- ការបន្តបញ្ចុះថ្លៃអគ្គិសនី ពង្រីកបណ្តាញគ្របដណ្តប់ និង បង្កើន ស្ថិរភាពអគ្គិសនី
- ការបន្តអភិវឌ្ឍការតភ្ជាប់ផ្នែកឌីជីថល
- ការពង្រឹងសមត្ថភាពស្ថាប័ន ក្នុងការធ្វើផែនការ ការរៀបចំថវិកា ការអនុវត្ត និង ការត្រួត ពិនិត្យ វាយតម្លៃគម្រោង។

# ១. ខ្លឹមសារនៃ ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

## ៤. ការធ្វើពិពិធកម្មសេដ្ឋកិច្ច (ត)

### ៤.២. ការអភិវឌ្ឍប្រភពកំណើនសេដ្ឋកិច្ចគន្លឹះ និង ថ្មីៗ

**រាជរដ្ឋាភិបាល ក្នុងនីតិកាលទី ៦ ផ្តោតអាទិភាពលើ៖**

- ការបន្តជំរុញការអនុវត្ត *"គោលនយោបាយអភិវឌ្ឍវិស័យឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥"*
- ការរៀបចំ និង អនុវត្តយុទ្ធសាស្ត្រការអភិវឌ្ឍវិស័យកាត់ដេរ និង ផលិតស្បែកជើង
- ការបន្តជំរុញកិច្ចដំណើរការ និង ទាក់ទាញការវិនិយោគនៅតាមតំបន់សេដ្ឋកិច្ចពិសេស
- ការរៀបចំផែនការមេអភិវឌ្ឍវិស័យទេសចរណ៍
- ការជំរុញការអភិវឌ្ឍវិស័យសេវាផ្នែកកំសាន្ត អក្សរសិល្ប៍ សិល្បៈ គំនូរជីវចល និង ភាពយន្ត
- ការជំរុញការអភិវឌ្ឍវិស័យប្រេងកាត និង ឧស្ម័ន

# ១. ខ្លឹមសារនៃ ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

## ៤. ការធ្វើពិពិធកម្មសេដ្ឋកិច្ច (ត)

### ៤.៣. ការរៀបចំខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថល និង ឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្មទី ៤

**រាជរដ្ឋាភិបាលក្នុងនីតិកាលទី ៦ នឹងផ្តោតអាទិភាពលើ៖**

- ការរៀបចំនិងអនុវត្តក្របខណ្ឌយុទ្ធសាស្ត្រសេដ្ឋកិច្ចឌីជីថលរយៈពេលវែង និងដាក់វិស័យឌីជីថល ជាអនុវិស័យនៅក្នុងប្រព័ន្ធគណនីជាតិ
- ការបន្តធ្វើបច្ចុប្បន្នភាព និង អនុវត្តគោលនយោបាយអភិវឌ្ឍវិស័យ ទូរគមនាគមន៍ និង បច្ចេកវិទ្យាគមនាគមន៍ និង ព័ត៌មាន, ផែនការមេបច្ចេកវិទ្យាគមនាគមន៍ និង ព័ត៌មាន
- ការបន្តពង្រឹង និង ពង្រីកការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រចាំបាច់
- ការជំរុញ និង ការបង្កើតមូលដ្ឋានគតិយុត្តគាំទ្រដល់ការអភិវឌ្ឍវិស័យ ឌីជីថល
- ការអភិវឌ្ឍជំនាញ និង ការអប់រំ ការបណ្តុះបណ្តាល ដោយផ្តោតលើការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលឱ្យបានទូលាយ
- ការអភិវឌ្ឍសហគ្រិនភាព និង ប្រព័ន្ធអេកូឡូស៊ីឌីជីថល ដែលជាបរិស្ថានអំណោយផលដល់ការបង្កើតធុរកិច្ច ថ្មីៗ

# ១. ខ្លឹមសារនៃ ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

## ៤. ការធ្វើពិពិធកម្មសេដ្ឋកិច្ច (ត)

### ៤.៤. ការជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និង ធនាគារ

**រាជរដ្ឋាភិបាលនីតិកាលទី ៦ នឹងផ្តោតទៅលើ៖**

- ការបន្តអនុវត្ត *"យុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុឆ្នាំ ២០១៦-២០២៥"* និង ការបន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ប្រចេញ-ចូលនៃប្រព័ន្ធទូទាត់ ការជំរុញការអភិវឌ្ឍប្រព័ន្ធទូទាត់ដោយប្រើបច្ចេកវិទ្យាហិរញ្ញវត្ថុ ការសម្របសម្រួលក្របខណ្ឌគោលនយោបាយ និង ក្របខណ្ឌគតិយុត្ត ការពង្រឹងសមត្ថភាពស្ថាប័ន និង ធនធានមនុស្ស
- ការបន្តធានាស្ថិរភាពហិរញ្ញវត្ថុ
- ការបន្តពង្រីកតួនាទីវិស័យធនាគារ ដើម្បីកៀរគរធនធានហិរញ្ញវត្ថុនៅក្នុងស្រុក
- ការបន្តអភិវឌ្ឍទីផ្សារមូលបត្រ
- ការសិក្សា និង រៀបចំឱ្យមានទីផ្សារសញ្ញាបណ្ណរដ្ឋ

# ១. ខ្លឹមសារនៃ ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

## ៤. ការធ្វើពិពិធកម្មសេដ្ឋកិច្ច (ត)

### ៤.៤. ការជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និង ធនាគារ

**រាជរដ្ឋាភិបាលនីតិកាលទី ៦ នឹងផ្តោតទៅលើ៖**

- ការជំរុញ និង លើកទឹកចិត្តដល់ការអភិវឌ្ឍ និង ការប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុ Fin Tech ក្នុងវិស័យធនាគារ និង ហិរញ្ញវត្ថុ
- ការលើកកម្ពស់ និង បង្កើនសមត្ថភាពវិភាគ តាមដាន និង ត្រួតពិនិត្យកិច្ចការប្រឆាំងការ សម្អាតប្រាក់ និង ហិរញ្ញប្បទានភេរវកម្ម។
- ការបន្តលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល ឱ្យកាន់តែទូលំទូលាយ
- ការបន្តពង្រឹង និង ពង្រីកផលិតផលធានារ៉ាប់រងថ្មីៗ

# ១. ខ្លឹមសារនៃ ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

## ៥- ការអភិវឌ្ឍវិស័យឯកជន និង ការងារ

### ៥.១. ការអភិវឌ្ឍទីផ្សារការងារ

**រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ ៖**

- ការបន្តពង្រឹងយន្តការ *"វេទិកាការងារ"* ការផ្តល់ការបណ្តុះបណ្តាលតម្រង់ទិសមុនចូល ធ្វើការ និង ការពង្រីកការផ្តល់សេវារកការងារ
- ការអនុវត្តច្បាប់ ស្តីពីប្រាក់ឈ្នួលអប្បបរមាដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការ ងារឱ្យមានប្រសិទ្ធភាព
- កម្មសិក្សា ដោយធ្វើវិសោធន-ការពង្រឹង និង ពង្រីកការអនុវត្តកម្មវិធីហ្វឹកហ្វឺនកូនជាង
- ការពង្រឹងគុណភាព និង ប្រសិទ្ធភាពអធិការកិច្ចការងារ
- ការពង្រឹងភាពសុខដុមរមនានៅក្នុងទំនាក់ទំនងវិជ្ជាជីវៈ
- ការបន្តពង្រឹងអភិបាលកិច្ចទេសន្តរប្រវេសន៍ការងារ និង ពង្រីកកិច្ចសហប្រតិបត្តិការពហុភាគី និង ទ្វេភាគី ដើម្បីបើកទូលាយទីផ្សារកាងារស្របច្បាប់នៅក្រៅប្រទេស
- ការបន្តពង្រីកការតបណ្តាញអគ្គិសនី និង ទឹកស្អាត ដោយតម្លៃទាបសមរម្យជូនកម្មករ-និយោជិត សិស្ស-និស្សិត

# ១. ខ្លឹមសារនៃ ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

## ៥- ការអភិវឌ្ឍវិស័យឯកជន និង ការងារ (ត)

### ៥.២- ការលើកស្ទួយសហគ្រាសធុនតូច និង មធ្យម និង សហគ្រិនភាព

**រាជរដ្ឋាភិបាលនឹងផ្ដោតអាទិភាពលើ៖**

- ការបញ្ចប់ការរៀបចំ និង ជំរុញការវត្ត "គោលនយោបាយគាំទ្រសហគ្រាសធុនតូច និង មធ្យម" ឱ្យមានប្រសិទ្ធភាព
- ការពង្រឹងការអនុវត្តយន្តការគាំទ្រ ដើម្បីជួយសម្រួលដល់ការចុះបញ្ជី
- ការបង្កើត "ធនាគារសហគ្រាសធុនតូច និង មធ្យម" ដើម្បីផ្ដល់ហិរញ្ញប្បទានដល់សហគ្រាសធុនតូច និង មធ្យម
- ការបង្កើត *"មូលនិធិជាតិសហគ្រិនភាព"* និង *"មជ្ឈមណ្ឌលអភិវឌ្ឍសហគ្រិនភាព"* ដោយសហការជាមួយ វិស័យឯកជន
- ការពង្រឹង និង ពង្រីកបន្ថែមការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធគាំទ្រ
- ការជំរុញការលើកកម្ពស់គុណភាពផលិតផលនៃសហគ្រាសធុនតូច និង មធ្យម

# ១. ខ្លឹមសារនៃ ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

## ៥- ការអភិវឌ្ឍវិស័យឯកជន និង ការងារ (ត)

### ៥.៣. ការរៀបចំ និង អនុវត្តភាពជាដៃគូវិស័យសាធារណៈ និង វិស័យឯកជន

**រាជរដ្ឋាភិបាលនឹងផ្ដោតអាទិភាពលើ៖**

- ការបន្តអនុវត្ត *"ឯកសារគោលនយោបាយស្ដីពីការអភិវឌ្ឍយន្តការ ភាពជាដៃគូរវាងរដ្ឋ និង ឯកជន សម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ២០១៦-២០២០"* និង ការរៀបចំ *"គោលនយោបាយអនុវត្តគម្រោងវិនិយោគសាធារណៈក្រោមយន្តការភាព ជា ដៃគូរវាងរដ្ឋ និង ឯកជន"*
- ការបន្តរៀបចំក្របខណ្ឌគតិយុត្ត និង បទប្បញ្ញត្តិពាក់ព័ន្ធ
- ការបន្តអភិវឌ្ឍសមត្ថភាពស្ថាប័ន និង ធនធានមនុស្ស តាមក្រសួង-ស្ថាប័នពាក់ព័ន្ធលើ ការគ្រប់គ្រង និង អនុវត្តគម្រោងតាមរូបភាពយន្តការភាពជាដៃគូរវាងរដ្ឋ និង ឯកជន
- ការបន្តអភិវឌ្ឍគម្រោងវិនិយោគសាធារណៈ តាមរយៈយន្តការភាពជាដៃគូរវាងរដ្ឋ និង ឯកជន

## ១. ខ្លឹមសារនៃ ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

### ៥- ការអភិវឌ្ឍវិស័យឯកជន និង ការងារ (ត)

### ៥.៤- ការពង្រឹងការប្រកួតប្រជែង

**រាជរដ្ឋាភិបាលនីតិកាលទី ៦ នឹងផ្តោតអាទិភាពលើ៖**

- ការជំរុញរៀបចំ និង អនុម័តច្បាប់ស្តីពីការប្រកួតប្រជែង
- ការពិនិត្យឡើងវិញ និង ធ្វើវិសោធនកម្មច្បាប់ស្តីពីក្ស័យធន
- ការជំរុញអនុវត្តយន្តការមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (Commercial Arbitration)
- ការបន្តជំរុញការរៀបចំ និង ការអនុវត្តស្តង់ដាទំនិញ សេវា និង ការគ្រប់គ្រង
- ការជំរុញរៀបចំ និង អនុម័តច្បាប់ស្តីពីការការពារអ្នកប្រើប្រាស់
- ការពង្រឹងយន្តការជំរុញការប្រកួតប្រជែងដោយស្មើភាព

# ១. ខ្លឹមសារនៃ ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

## ៦. ការអភិវឌ្ឍប្រកបដោយចីរភាព និង បរិយាប័ន្ន

### ៦.១. ការលើកស្ទួយវិស័យកសិកម្ម និង ការអភិវឌ្ឍជនបទ

**រាជរដ្ឋាភិបាលនឹងផ្តោត អាទិភាពលើ៖**

- ការជំរុញការរៀបចំ និង ដាក់ឱ្យអនុវត្ត *"ផែនការមេសម្រាប់អភិវឌ្ឍវិស័យកសិកម្មឆ្ពោះទៅ ឆ្នាំ ២០៣០"* និង *"ផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យកសិកម្មឆ្នាំ ២០១៩-២០២៣"*
- ការបន្តជំរុញការរៀបចំ អនុមតិ និង ការអនុវត្ត *"ច្បាប់ស្តីពីការការពាររុក្ខជាតិ និង ភូតគាមអនាម័យ"* និង *"ច្បាប់ស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា"*
- ការបង្កើនផលិតភាព គុណភាព និង ពិពិធកម្ម
- ការលើកកម្ពស់ឧស្សាហកម្មកែច្នៃ
- ការបន្តជំរុញការដាំបន្លែគ្រប់ប្រភេទជំនួសឱ្យការនាំចូល និង ការ រៀបចំបង្កើតទីផ្សារ បោះដុំ និង ចែកចាយបន្លែ ដែលមានស្តង់ដា និង អនាម័យខ្ពស់
- ការជំរុញពាណិជ្ជូបនីយកម្មកសិកម្ម

# ១. ខ្លឹមសារនៃ ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

## ៦. ការអភិវឌ្ឍប្រកបដោយចីរភាព និង បរិយាប័ន្ន (ត)

### ៦.១. ការលើកស្ទួយវិស័យកសិកម្ម និង ការអភិវឌ្ឍជនបទ

- ការជំរុញការចិញ្ចឹមសត្វ និង វារីវប្បកម្ម តាមរយៈការបន្តអនុវត្ត *"ច្បាប់ស្តីពីសុខភាពសត្វ និង ផលិតកម្មសត្វ" "ក្របខណ្ឌផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យបសុសត្វ ឆ្នាំ ២០១៦-២០២៥"* និង *"ផែនការយុទ្ធសាស្ត្រជាតិអភិវឌ្ឍវារីវប្បកម្មឆ្នាំ ២០១៦-២០៣០"*។
- ការពង្រឹងការគ្រប់គ្រងជីសម្បទានសេដ្ឋកិច្ច ការបន្តជំរុញការបោសសម្អាតមីន និង យុទ្ធភណ្ឌមិនទាន់ផ្ទុះ និង ការបន្តផ្តល់ដីសម្បទានសង្គមកិច្ច ដល់គ្រួសារក្រីក្រ
- ការធ្វើវិចារណកម្មក្នុងការវិនិយោគលើប្រព័ន្ធធារាសាស្ត្រ
- ការបន្តជំរុញការអភិវឌ្ឍជនបទឱ្យរស់រវើក ដោយបន្តវិនិយោគលើផ្លូវជនបទ ប្រព័ន្ធ ធារាសាស្ត្រខ្នាតតូច ការពង្រីកការគ្របដណ្តប់ការប្រើប្រាស់អគ្គិសនី ការពង្រីកការ ទទួលបានទឹកស្អាត ការលើកកម្ពស់អនាម័យ

# ១. ខ្លឹមសារនៃ ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

## ៦. ការអភិវឌ្ឍប្រកបដោយចីរភាព និង បរិយាប័ន្ន (ត)

### ៦.២- ការគ្រប់គ្រងធនធានធម្មជាតិ និង វប្បធម៌ ប្រកបដោយចីរភាព

**រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ៖**

- ការជំរុញអនុវត្ត *"គោលនយោបាយជាតិស្តីពីធនធានរ៉ែ ឆ្នាំ២០១៨-២០២៨"*
- ការពង្រឹងយន្តការគ្រប់គ្រងធនធាន និង អាជីវកម្មខ្សាច់
- ការបន្តគ្រប់គ្រងធនធានព្រៃឈើ និង សត្វព្រៃ ដោយថែរក្សាគម្របព្រៃឈើឱ្យលើស ៦០% នៃផ្ទៃប្រទេស ការលើកកម្ពស់ការអភិរក្សព្រៃឈើ និង សត្វព្រៃ
- ការបន្តជំរុញការអភិរក្ស និង គ្រប់គ្រងធនធានជលផល
- ការលើកកម្ពស់ការថែរក្សាប្រព័ន្ធអេកូឡូស៊ី និង ការការពារតំបន់ធម្មជាតិ
- ការបន្តអភិរក្ស និង អភិវឌ្ឍបេតិកភណ្ឌវប្បធម៌ ដោយជំរុញការចុះបញ្ជី, ពង្រឹងការគ្រប់ គ្រង ការសិក្សាស្រាវជ្រាវ និង ចងក្រង ព្រមទាំងការបង្កើត តម្លៃពីបេតិកភណ្ឌវប្បធម៌។

# ១. ខ្លឹមសារនៃ ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

## ៦. ការអភិវឌ្ឍប្រកបដោយចីរភាព និង បរិយាប័ន្ន (ត)

### ៦.៣- ការពង្រឹងការគ្រប់គ្រងនគរូបនីយកម្ម

**រាជរដ្ឋាភិបាលនឹងផ្ដោតអាទិភាពលើ ៖**

- ការបន្តជំរុញដំណើរការកែទម្រង់ដីធ្លី និង ការបង្កើនល្បឿននៃការ កសាងផែនការមេ និង ប្លង់គោលនៃការរៀប ចំដែនដី នគរូបនីយកម្ម និង សំណង់ ទាំងថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ
- ការពង្រឹងសមត្ថភាពអនុវត្តការងារនគរូបនីយកម្ម
- ការរៀបចំផែនការមេអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទីក្រុង និង ទីប្រជុំជនសំខាន់ៗ
- ការជំរុញការអភិវឌ្ឍវិស័យសំណង់ និង ការរៀបចំទីក្រុង ទីប្រជុំជន ពិសេសក្រុងប៉ោយ ប៉ែត និង ក្រុងបាវិត
- ការបន្តពង្រឹងសោភ័ណភាព និង សេវាទីក្រុង ទីប្រជុំជនសំខាន់ៗ

# ១. ខ្លឹមសារនៃ ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

## ៦. ការអភិវឌ្ឍប្រកបដោយចីរភាព និង បរិយាប័ន្ន (ត)

### ៦.៤- ការធានាចីរភាពបរិស្ថាន និង ការរៀបចំខ្លួនឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ

**រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ៖**

- ការបន្តអនុវត្ត *"ផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតង ២០១៣-២០៣០" "ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ២០១៤-២០២៣" "យុទ្ធសាស្ត្រ និង ផែនការសកម្មភាពបរិស្ថានជាតិ ២០១៦-២០២៣" "ផែនការយុទ្ធសាស្ត្រវេជបូកជាតិ"*
- ការបន្តពង្រឹងការគ្រប់គ្រងតំបន់ការពារធម្មជាតិ អភិរក្សជីវៈចម្រុះ អភិរក្សសម្បត្តិធម្មជាតិ ពិសេសប្រព័ន្ធអេកូឡូស៊ីបឹងទន្លេសាប ទន្លេមេគង្គ និង តំបន់ឆ្នេរ
- ការបន្តពង្រឹងការគ្រប់គ្រងសំណល់រឹង រាវ ឧស្ម័ន និង សារធាតុ គ្រោះថ្នាក់
- ការបង្កើនការប្រើប្រាស់បច្ចេកវិទ្យាភាតរបរិស្ថាន និង ភាតរអាកាសធាតុ ក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និង ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច

# ១. ខ្លឹមសារនៃ ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

## ៦. ការអភិវឌ្ឍប្រកបដោយចីរភាព និង បរិយាប័ន្ន (ត)

### ៦.៤- ការធានាចីរភាពបរិស្ថាន និង ការរៀបចំខ្លួនឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ

- ការបន្តជំរុញការអនុវត្តយន្តការពាណិជ្ជកម្មកាបូន និង ក្របខណ្ឌគតិយុត្តពាក់ព័ន្ធ ការពង្រឹងសមត្ថភាពរៀបចំ និង អនុវត្តវិធានការ ដើម្បីបន្សាំ និង ធន់ទៅនឹងការប្រែប្រួលអាកាសធាតុ
- ការបន្តជំរុញការអភិវឌ្ឍ និង អនុវត្តផែនការគ្រប់គ្រងទឹកចម្រុះ
- ការបន្តការលើកទឹកចិត្ត និង បង្កើនការវិនិយោគលើថាមពលស្អាត និង ថាមពលកកើត ឡើងវិញ
- ការបន្តពង្រឹងក្របខណ្ឌគតិយុត្ត ព្រមទាំងការសិក្សាស្រាវជ្រាវ និងការអភិវឌ្ឍសមត្ថភាពជំនាញ និង ចំណេះដឹងដល់មន្ត្រីថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ លើផ្នែកបរិស្ថាន ការអភិវឌ្ឍបៃតង ការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងធនធានទឹកចម្រុះ និង ការប្រើ ប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព។

# ២. បរិមាណទុនសរុប ដែលត្រូវការសម្រាប់ការវិនិយោគរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីអនុវត្តសកម្មភាពអាទិភាព

| តម្រូវការការវិនិយោគសាធារណៈសរុប | ២០១៩-២០២៣ | |
|---|---|---|
| | លានដុល្លា | ពាន់លានរៀល |
| ការវិនិយោគសាធារណៈសរុប | ១៦ ៤៥៤ | ៦៧ ៤៧៩ |
| ហិរញ្ញប្បទានក្នុងស្រុក | ៧ ០០០ | ២៨ ៧០០ |
| ហិរញ្ញប្បទានពីក្រៅប្រទេស | ៨ ១៥៤ | ៣២ ៦១៥ |
| | | |
| ការវិនិយោគឯកជនសរុប | ៤៣ ៤៣៨ | ១៧៨ ០៩៦ |
| ហិរញ្ញប្បទានក្នុងស្រុក | ១៧ ១០៧ | ៧០ ១៣៨ |
| ហិរញ្ញប្បទានពីក្រៅប្រទេស | ២៦ ៣៣១ | ១០៧ ៩៥៧ |
| ***ការវិនិយោគសរុប*** | ***៥៩ ៨៩០*** | ***២៤៥ ៥៧៤*** |

ចំណាំ៖ ១ដុល្លា= ៤១០០រៀល

# ២. តារាងទី ៥.៣: ការបែងចែកតាមវិស័យនិងអនុវិស័យនៃវិនិយោគវិស័យសាធារណៈក្នុងផ.យ.អ.ជ. ២០១៩-២០២៣

| វិស័យ | ភាគរយ | បរិមាណវិភាជន៍ ២០១៩-២០២៣ | |
|---|---|---|---|
| | | ប៊ីលានរៀល | ប៊ីលានដុល្លារអាមេរិក |
| វិស័យសង្គមកិច្ច | ៣២ | ៣០,៨ | ៧,៥ |
| អប់រំ | ១០ | ៩,៦ | ២,៣ |
| បច្ចេកទេសនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ៨ | ៧,៨ | ១,៨ |
| សុខាភិបាល | ១០ | ៩,៦ | ២,៤ |
| កិច្ចគាំពារសង្គម/ការកាត់បន្ថយភាពក្រីក្រ | ៤ | ៣,៨ | ១,០ |
| វិស័យសេដ្ឋកិច្ច | ២៤ | ២៣,០ | ៥,៦ |
| កសិកម្មនិងការគ្រប់គ្រងដីធ្លី | ៤ | ៣,៨ | ១,០ |
| ដំណាំតាមរដូវ៖ ស្រូវនិងផ្សេងៗ | ៤ | ៣,៨ | ១,០ |
| អភិវឌ្ឍន៍ជនបទ | ១២ | ១១,៦ | ២,៧ |
| កម្មន្តសាល រ៉ែ និងពាណិជ្ជកម្ម | ៤ | ៣,៨ | ១,០ |
| វិស័យហេដ្ឋារចនាសម្ព័ន្ធ | ២១ | ២០,២ | ៥,០ |
| ដឹកជញ្ជូន (ផ្លូវថ្នល់ កំពង់ផែ ផ្លូវដែក អាកាសចរណ៍) | ១២ | ១១,៦ | ២,៧ |
| ទឹកនិងអនាម័យ (មិនគិតនៅជនបទ) | ៤ | ៣,៨ | ១,០ |
| ថាមពល និងអគ្គិសនី | ៤ | ៣,៨ | ១,០ |
| ប្រៃសណីយ៍និងទូរគមនាគមន៍ | ១ | ១,០ | ០,២ |
| សេវាកម្មនិងកម្មវិធីអន្តរវិស័យ | ២១ | ២០,២ | ៥,០ |
| ការបញ្ជ្រាបយេនឌ័រ | ១,៥ | ១,៤ | ០,៤ |
| ទេសចរណ៍ | ២ | ២,០ | ០,៥ |
| បរិស្ថាននិងការអភិវឌ្ឍ | ៤ | ៣,៨ | ១,០ |
| សហគមន៍និងសេវាកម្មសង្គម | ៤ | ៣,៨ | ១,០ |
| វប្បធម៌និងសិល្បៈ | ១,៥ | ១,៤ | ០,៤ |
| អភិបាលកិច្ចនិងរដ្ឋបាល | ៨ | ៧,៨ | ១,៨ |
| មិនទាន់បែងចែក | ២ | ២,០ | ០,៥ |
| *សរុបរួម* | *១០០* | *៩៦,៤* | *២៣,៥* |

# ៣. ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ

- ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ លើសកម្មភាពនានា ដែលអនុវត្តដោយ ក្រសួង ស្ថាប័ន នានា គឺជាកាងារដ៏សំខាន់របស់ដំណើរការការងារផែនការ។
- វឌ្ឍនភាពនៃការអនុវត្ត ផ.យ.អ.ជ. នឹងត្រូវបានធ្វើការតាមដានត្រួតពិនិត្យ ប្រចាំឆ្នាំ និងវាយតម្លៃពាក់កណ្តាលអាណត្តិ។
- ដូចបានកំណត់ក្របខ័ណ្ឌលទ្ធផល ត្រូវបានជ្រើសរើសជាឧបករណ៍ សម្រាប់តាមដានត្រួតពិនិត្យនិងវាយតម្លៃ ការអនុវត្ត ផ.យ.អ.ជ.។
- ក្របខ័ណ្ឌលទ្ធផលត្រូវការចាំបាច់នូវភស្តុតាង ដូចនេះការប្រមូលទិន្នន័យជាស៊េរីសម្រាប់ផ្ទៀងផ្ទាត់ចំណុចដៅនានានៃសូចនាករស្នូលរបស់ផែនការ។

# ៣. ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ (ត)

- បញ្ជីសូចនាករស្នូល សម្រាប់តាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្ត *ផ.យ.អ.ជ. ២០១៩-២០២៣* ត្រូវបានរៀបចំឡើង ដោយជ្រើសរើសពី ក្របខ័ណ្ឌ គ.អ.ច.ក. ក្របខ័ណ្ឌយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ ផ.យ.អ.ជ. ២០១៤-២០១៨ និង សូចនាករថ្មីស្នើឡើងពីក្រសួង ស្ថាប័ននិងមានការឯកភាពពីក្រសួងផែនការ។
- សេចក្តីព្រាងបញ្ជីសូចនាករ **មានសូចនាករស្នូលចំនួន១០៩** **និង** **តារាងសូចនាករបន្ថែមចំនួន ៤៩** ។

# ៣. ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ (ត)

## ប្រភពនៃសូចនាករ ផ.យ.អ.ជ. ២០១៩-២០២៣



# ៣. ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ (ត)

- ការងារតាមដានត្រួតពិនិត្យនិងវាយតម្លៃ ការអនុវត្ត *ផ.ព.អ.ជ. ២០១៩-២០២៣* នឹងត្រូវធ្វើឡើងជារៀងរាល់ឆ្នាំ។
- ការពិនិត្យមើលពីលទ្ធផលពាក់កណ្តាលអាណត្តិ នឹងត្រូវនៅឆ្នាំ២០២១។
- ការងាររៀបចំ *ផ.ព.អ.ជ. ២០២៤-២០២៨* នឹងត្រូវចាប់ផ្តើមនៅដើមឆ្នាំ ២០២៣។

# សូមអរគុណ !